# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុប្រជុំ

## ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

ឆ្នាំ ពីពាន់ម្ភៃបី ខែ មីនា ទី ម្ភៃប្រាំបួន ម៉ោង បី រសៀល នៅក្នុងរោងចក្រ **អេច អិម ប្លាស់ស្ទិច ខូ អិលធីឌី** ដែលមានអាស័យដ្ឋាននៅ ភូមិ បូរីកម្មករ ឃុំ បែកចាន ស្រុក អង្គស្នួល ខេត្ត កណ្តាល បានបើកកិច្ចប្រជុំស្តីពីការព្យួរការងារកម្មករនិយោជិតចំនួន ១៦ នាក់ ក្នុងរយៈពេល ០២ ខែ គិតចាប់ពីថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០២៣ ។

1- សមាសភាពចូលរួមអង្គប្រជុំមានដូចខាងក្រោមះ

-លោក KIM JEONG YOUB នាយករោងចក្រ

-លោកស្រី ជា សុចិន្តា ប្រធានផ្នែកគណនេយ្យ

-លោក សន ស៊ីណាន ប្រធានរដ្ឋបាល

-លោក កែវ សុជា តំណាងកម្មករ

-លោក កឹង សុជាត ប្រធានផ្នែក

-លោក ចាន់ វាសនា ប្រធានផ្នែក

-លោក ពៀន ចិន្តា ប្រធានផ្នែក

ជាកិច្ចចាប់ផ្តើម នៃអង្គប្រជុំ លោក **KIM JEONG YOUB** ដែលជានាយកគ្រប់គ្រងរោងចក្រ បានសម្របសម្រួលក្នុងអង្គប្រជុំបានធ្វើការពន្យល់ណែនាំអំពីការខ្វះខាតនូវ ការបញ្ជាទិញពីភ្ញៀវ ជាពិសេសបច្ចុប្បន្ននេះ គ្រប់រោងចក្រសហគ្រាសកាត់ដេរសម្លៀកបំពាក់ដែលធ្លាប់ធ្វើការបញ្ជាទិញនោះបានទទួលរងនូវផលប៉ះពាល់អត់មានការបញ្ជាទិញពីភ្ញៀវបរទេសដែរ ។ ដូច្នេះជាហេតុធ្វើអោយរោងចក្រ អេច អិម ប្លាស់ស្ទិច ខូ អិលធីឌី សម្រេចទាំងបង្ខំចិត្តធ្វើការព្យួរកិច្ចសន្យាការងាររបស់បងប្អូន-កម្មករនិយោជិតមួយចំនួនតាមផ្នែក ។

ក្រោយពីឆ្លងកាត់ការប្រជុំពិភាក្សារួចមក ភាគីទាំងពីរបានសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៦នាក់ដូចមានភ្ជាប់ក្នុងបញ្ជីឈ្មោះ ក្នុងរយៈពេល ០២ខែ ចាប់ពីថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០២២ រហូតដល់ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០២៣ និង ត្រូវចូលធ្វើការ

ព្រះរាជាណាចក្រកម្ពុជា អេច.អិម ប្លាស់ស្ទិច ខូ អិលធីឌី H.M PLASTIC CO., LTD. ស្នាក់ការខេត្តកណ្តាល

ជាធម្មតាវិញនៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២៣ តាមកាលកំណត់ ( ថ្ងៃឈប់សម្រាកអាចផ្លាស់ប្តូរ ទៅតាមស្ថានភាព ) ។

ក្រុមហ៊ុនបានឯកភាពផ្តល់ប្រាក់ឧបត្ថមចំនួន ៧០ដុល្លារ ( ចិតសិបដុល្លារអាមេរិក ) ក្នុងមួយខែសម្រាប់ការព្យួរកិច្ចសន្យានេះជូនបងប្អូនកម្មករនិយោជិតទាំងអស់ ហើយការបើកប្រាក់ឧបត្ថមចំនួន ៧០ដុល្លារនេះ គឺបើកនៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២៣ គឺសម្រាប់ខែ មេសា និង បើកម្តងទៀត នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២៣ គឺសម្រាប់ខែ ឧសភា ឆ្នាំ ២០២៣ តែម្តង។

កំណត់ហេតុអង្គប្រជុំនេះត្រូវបានបញ្ចប់ទៅនៅថ្ងៃខែឆ្នាំ ដដែលក្រោមបរិយាកាសយោគយល់អធ្យាស្រ័យ និង ស្មទ្ធិស្នាលក្រៃលែង ។

ថ្ងៃ ពុធ ៨កើត ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២៣

ហត្ថលេខា និង ត្រាក្រុមហ៊ុន

លោក KIM JEONG YOUB

ប្រធានរដ្ឋបាល

លោក សន ស៊ីណាន

ហត្ថលេខាអ្នកធ្វើកំណត់ហេតុ

លោកស្រី ជា សុចិន្តា

## ស្នាមមេដៃតំណាងកម្មករ និង ប្រធានផ្នែក

លោក កែវ សុជា | លោក គឹង សុជាត | លោក ចាន់ វាសនា | លោក ពៀន ចិន្តា